ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ៩៤.០២៤.១៧០១ ស.ន.ណ

ថ្ងៃអង្គារ ៤កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង
## ស្តីពី
## កម្មវិធីប្រឡងជ្រើសរើសបុគ្គលិក

យោងសេចក្តីជូនដំណឹងលេខ ធ៨.០២៤.៩២៨ សជណ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤

ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនដំណឹងដល់បេក្ខជនដែលបានដាក់ពាក្យប្រឡងចូលបម្រើការងារនៅអគ្គនាយកដ្ឋានគោលនយោបាយនិងសហប្រតិបត្តិការអន្តរជាតិ នៃធនាគារជាតិនៃកម្ពុជា ក្នុង**ក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ធនាគារជាតិនៃកម្ពុជា"ក" កម្រិតសញ្ញាបត្រអនុបណ្ឌិត ឬបណ្ឌិតផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុ ឬធនាគារ** ឱ្យបានជ្រាបថា **ការប្រឡងជ្រើសរើស** នឹងប្រព្រឹត្តទៅតាមកម្មវិធីដូចខាងក្រោម៖

- កាលបរិច្ឆេទប្រឡង ៖ **ថ្ងៃអង្គារ ១៥កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤ វេលាម៉ោង ២:៣០ នាទីរសៀលតទៅ**
- មណ្ឌលប្រឡង ៖ **អគារធនាគារជាតិនៃកម្ពុជា សែនសុខ**
- វិញ្ញាសាប្រឡង ៖
  - ការប្រឡងតាមប្រព័ន្ធ General Aptitude Test
  - ការប្រឡងវិញ្ញាសាសរសេរជំនាញសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងធនាគារ ជាភាសាអង់គ្លេស។

**<u>បញ្ជាក់</u>** ៖ បេក្ខជន ត្រូវអញ្ជើញមកពិនិត្យឈ្មោះ និងលេខតុប្រឡងក្នុងបញ្ជីឈ្មោះបេក្ខជនប្រឡង ដែលនឹងបិតផ្សាយ**ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៤** នៅអគារធនាគារជាតិនៃកម្ពុជា សែនសុខ។

ត.ប.ទេសាភិបាល
អគ្គលេខាធិការ

គ្រួយ វាសនា